# មជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ចាម

## រឿងរ៉ាវកើតឡើងក្នុងភូមិទី៨ ឃុំ/ស្រុកកោះសូទិន ក្នុងរបបខ្មែរក្រហម

ស្រាវជ្រាវ និងសរសេរដោយ៖  លី ដេវីត, សាំង ចាន់ធូ, និងទូច វណ្ណេត
ពិនិត្យដោយ៖ ស៊ាង ចិន្តា

ចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២៤



ទិដ្ឋភាពពីលើអាកាសនៅភូមិទី៨ ឃុំ/ស្រុកកោះសូទិន ខេត្តកំពង់ចាម។
(សាំង ចាន់ធូ/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាតិកា

**១. សេចក្តីផ្តើម** ........................................ ទំព័រ៣-៤

**២. អ្នកគូមិទីផ ក្នុងរបបខ្មែរក្រហម**

**ប្រជាជនចាស់ (ហៅថាពួកប្រជាជន៧០) ដែលទទួលបានការទុកចិត្តពីខ្មែរក្រហម**

«ប្រធានកងចល័តនារីខ្មែរក្រហម» ឡុង គឹមស្រ៉ាង ........................................ ទំព័រ៥-៦

«កងនេសាទខ្មែរក្រហម» លឹម អេង ........................................ ទំព័រ៦-៩

«កងចល័តនារីខ្មែរក្រហម» ហុក ណៃវេង ........................................ ទំព័រ១០-១១

**ប្រជាជនកណ្តាល (ហៅថា ពួកប្រជាជន៧៣)**

«កងចល័តវ័យកណ្តាល និងការត្រៀមយកទៅវាយសម្លាប់» អាន រី ........................................ ទំព័រ១១-១២

«កងចល័តនារីវ័យកណ្តាល» ស៊ឹង គឹមស្រ៊ុន ........................................ ទំព័រ១២-១៣

**ប្រជាជនថ្មី (ហៅថាពួកប្រជាជន៧៥)**

«មិត្តកុមារភាពអាចត្រឹមជួយសង្គ្រោះជីវិតខ្ញុំ .....» ម៉ៅ វណ្ណា ........................................ ទំព័រ១៤-១៥

«ជីវិតនៃការរត់គៀសខ្លួនចេញពីសង្គ្រាម .....» ជី វាសនា ........................................ ទំព័រ១៦-១៧

«ខ្មែរក្រហមសម្លាប់ឪពុកម្តាយ .....» ស្រេង ស៊ីថា ........................................ ទំព័រ១៨-២០

**៣. សេចក្តីបញ្ចប់** ........................................ ទំព័រ២១

**៤. ឯកសារយោង** ........................................ ទំព័រ២២

## ១. សេចក្ដីផ្ដើម

ភូមិទី៨ គឺជាភូមិមួយក្នុងចំណោមភូមិទាំង១៤ ចំណុះរដ្ឋបាលឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ភូមិទី៨ មានប្រជាជនសរុបចំនួន ៣៧៨នាក់ (ស្រី១៩៨ នាក់) និងសរុបចំនួន ១៤៤គ្រួសារ។ ភូមិទី៨ មានលក្ខណៈជាភូមិសាស្ត្រកោះ ដែលហ៊ុមព័ទ្ធទៅដោយទន្លេមេគង្គ និងព្រៃក ហើយមានចម្ងាយប្រហែល ២០គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម។

បន្ទាប់ពីរដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០ អ្នកភូមិជាច្រើនបានចូលរួមធ្វើបាតុកម្មដង្ហែទៅទីរួមខេត្តកំពង់ចាម។ របប លន់ នល់ បានធ្វើការបង្ក្រាបបាតុករ ដែលមានអ្នកភូមិមួយចំនួនបានរត់វិលត្រលប់មកភូមិវិញ។ មិនយូរប៉ុន្មាន ទាហាន លន់ នល់ ចុះរៀបចំអាជ្ញាធរគ្រប់គ្រងមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតកងស្វ័យការពារនៅភូមិសាស្ត្រកោះសូទិន។

នៅចុងឆ្នាំ១៩៧០ កងទ័ពខ្មែរក្រហម ត្រូវបានបញ្ជូនមកដល់ភូមិទី៨ ហើយសុំផ្ទះរបស់អ្នកភូមិស្នាក់នៅ។ បន្ទាប់មក ទាហាន លន់ នល់ ត្រូវបានបញ្ជូនមកដែរ ដើម្បីវាយបណ្ដេញកងទ័ពខ្មែរក្រហមចេញ។ កងទ័ព ខ្មែរក្រហម ត្រូវបានដកចេញពីភូមិទៅលាក់ខ្លួននៅក្នុងព្រៃនៅស្រុកជីហែរ និងស្រុកអូររាំងឪ ដែលជាទីកន្លែងលាក់ខ្លួនតស៊ូរបស់កងទ័ពខ្មែរក្រហម។ យ៉ាងណាក៏ដោយ កងទ័ពខ្មែរក្រហម ត្រូវបានបញ្ជូនចូលមកភូមិវិញជាបន្តបន្ទាប់។

សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ចាប់ផ្ដើមផ្ទុះឡើងកាន់តែខ្លាំងឡើងរហូតដល់ឆ្នាំ១៩៧៣។[1] កងទ័ពខ្មែរក្រហមបានវាយរំដោះ និងគ្រប់គ្រងភូមិនានានៅកោះសូទិនជាបន្តបន្ទាប់ និងត្រៀមបន្តប្រយុទ្ធជាមួយទាហាន លន់ នល់ យ៉ាងក្លៀវក្លា ជួនពេលខ្លះសង្គ្រាមបានអូសបន្លាយអស់រយៈពេល ៧យប់៧ថ្ងៃ។ អ្នកភូមិទី៨ ស្ថិតនៅចំកណ្ដាលនៃសមរភូមិប្រទាញប្រទង់ ហើយត្រូវធ្វើការសម្រេចចិត្តបង្ខំរត់គៀសខ្លួនចេញពីភូមិទៅកាន់ទីកន្លែងសុវត្ថិភាពមិនប្រាកដប្រជា។ អ្នកភូមិមួយចំនួនរត់គៀសខ្លួនទៅកាន់តំបន់រំដោះខ្មែរក្រហម ដែលខ្លួនអាចទៅដល់ និងមានបងប្អូនកំពុងរស់នៅទីនោះ រួមមានស្រុកជីហែរ និងស្រុកអូររាំងឪ ជាដើម។ អ្នកភូមិខ្លះទៀត រត់គៀសខ្លួនទៅទីរួមខេត្តកំពង់ចាម ដែលខ្លួនគិតថាជាទីសុវត្ថិភាព និងមានទាហាន លន់ នល់ ឈរជើងយ៉ាងរឹងមាំមិនឱ្យសត្រូវចូលមកក្បែរបាន។ ចំណែកឯ អ្នកភូមិមួយចំនួនតូច បានសម្រេចចិត្តធ្វើដំណើរទៅទីក្រុងភ្នំពេញជាទីកន្លែងដែលមានបងប្អូនរស់នៅ និងសុវត្ថិភាពបំផុតរបស់ជនភៀសខ្លួន។

នៅចន្លោះឆ្នាំ១៩៧២ និង១៩៧៣ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើងៗស្របពេលដែលកងទ័ពខ្មែរក្រហមកំពុងរំដោះភូមិសាស្ត្រជាច្រើនទៀតនៅខេត្តកំពង់ចាម។ ត្រឹម

[1] ផេង ពង្សរ៉ាស៊ី, ដេវីដ ឆេដល័រ, គ្រីស្តូហ្វ័រ ឌៀរីង, សុភ័ក្រ ភាណា, «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» (បោះពុម្ពលើកទី២ នៅប្រទេសកម្ពុជា ឆ្នាំ២០២០) ទំព័រ ២៨។

ពាក់កណ្តាលឆ្នាំ១៩៧៣ កងទ័ពខ្មែរក្រហម បានវាយចូលដល់ទីរួមខេត្តកំពង់ចាម និងបានរំដោះផ្នែកខ្លះនៃទីរួមខេត្ត។ កងទ័ពខ្មែរក្រហម បានជម្លៀសប្រជាជនចេញពីផ្ទះសម្បែងរបស់ខ្លួនឱ្យទៅនៅទីជនបទនានា ឬទៅរស់នៅភូមិកំណើតរបស់ខ្លួន។

បន្ទាប់ពីកងទ័ពខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីរួមខេត្តកំពង់ចាមក៏ត្រូវបានរំដោះដែរ។ ខ្មែរក្រហមចាប់ផ្តើមរៀបចំ និងបែងចែងក្រុមប្រជាជន ដូចជា ប្រជាជនចាស់ ហៅថាពួកប្រជាជន៧០ គឺជាក្រុមប្រជាជនដែលត្រូវបានកងទ័ពខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧០។ ប្រជាជនដែលកងទ័ពរំដោះខ្មែរក្រហម ចូលមករំដោះបាននៅឆ្នាំ១៩៧៣ ត្រូវបានចាត់ទុកថា ប្រជាជនកណ្តាល (ឬហៅថា ប្រជាជន៧៣)។ចំណែកឯ ប្រជាជនថ្មី ហៅថាពួកប្រជាជន៧៥ គឺជាក្រុមប្រជាជនដែលត្រូវបានកងទ័ពខ្មែរក្រហមជម្លៀសមកភូមិ ហើយក្រុមប្រជាជនទាំងអស់នេះ ត្រូវបានខ្មែរក្រហមសម្លាប់ច្រើនជាងគេ។

ក្នុងចំណោមក្រុមប្រជាជនទាំងនេះ ប្រជាជនថ្មី (ពួកប្រជាជន៧៥) ទទួលរងគ្រោះខ្លាំងជាងគេ ព្រោះត្រូវបានខ្មែរក្រហមសម្លាប់ជាបន្តបន្ទាប់។ ការសម្លាប់ប្រជាជនថ្មី កើតឡើងកាន់តែខ្លាំងឡើងៗ នៅពេលដែល កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងនៅឆ្នាំ១៩៧៧ ដើម្បីអនុវត្តគោលនយោបាយបន្សុទ្ធកម្ម។[2]

បន្ទាប់ពីកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហម ចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងដោយបង្ខំ ហើយប្រជាជនថ្មីមួយចំនួនបានមកដល់ភូមិទី៨។ នៅឆ្នាំ១៩៧៥ដដែល អ្នកភូមិទី៨ ត្រូវបានដាក់ឱ្យធ្វើស្រែប្រវាស់ដៃរយៈពេលជាច្រើនខែ ដើម្បីចែកស្រូវអង្ករគ្នាហូប។ រហូតដល់ឆ្នាំ១៩៧៦ សហករណ៍ត្រូវបានបង្កើតឡើង ទើបខ្មែរក្រហម ដាក់អ្នកភូមិឱ្យធ្វើការងារតាមកងនីមួយៗ ដូចជា កងកុមារ កងចល័តយុវជន-យុវនារី កងចល័តវ័យកណ្តាល និងកងជរា នៅតាមទិសដៅផ្សេងៗគ្នា។ ប្រជាជន៧០ ប្រជាជន៧៣ និងប្រជាជន៧៥ ត្រូវបានដាក់កំណត់ការងារផ្សេងៗគ្នា។ ប្រជាជន៧០ ទទួលបានការទុកចិត្តពីខ្មែរក្រហម ហើយឱ្យគ្រប់គ្រងលើប្រជាជន៧៣ និងប្រជាជន៧៥ ដែលរស់នៅភូមិទី៨។

អ្នកភូមិទី៨ និងប្រជាជន៧៥ ត្រូវបានយកសម្លាប់នៅវត្តក្បាលកោះ និងបរិវេណជុំវិញនោះ។ ការកាប់សម្លាប់អ្នកភូមិ និងប្រជាជនថ្មី កើតឡើងកាន់តែខ្លាំងឡើងចាប់ពីឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨ គឺនៅពេលដែលកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រង។ កម្មាភិបាលកម្រិតមូលដ្ឋាន ដូចជា ប្រធានភូមិ មេកង ឬមេក្រុម និងប្រជាជន៧៥ ដែលនៅសេសសល់ និងប្រជាជន៧៣ ដែលប្រព្រឹត្តិកំហុសធ្ងន់ ត្រូវបានបណ្តើរ ឬដឹកទាំងកាណូតពីត្រើយម្ខាងយកទៅសម្លាប់នៅវត្តក្បាលកោះ និងបរិវេណជុំវិញនោះ។ ទោះបីជាមានទឹកជំនន់លិចភូមិនៅខែវស្សា ឆ្នាំ១៩៧៨ ក៏ដោយ ការកាប់សម្លាប់របស់ខ្មែរ

---

(2) ស្ងួន, ទំព័រ៤៨-៥១។

ក្រហមនៅតែបន្តមិនឈប់ឈរ។ កម្មាភិបាលខ្មែរក្រហមកពីភូមិភាគនិរតី ចាប់ប្រជាជន និងដឹកតាមកាណូតយកទៅសម្លាប់ និងបោះចូលទន្លេ ដែលងាយបំបាត់ភស្តុតាងឃើញនឹងភ្នែកនៃការសម្លាប់មនុស្សរបស់ពួកគេ។

## ២. អ្នកភូមិទី៨ ក្នុងរបបខ្មែរក្រហម

នៅក្នុងរបបខ្មែរក្រហម អ្នកភូមិទី៨ ដែលបានរត់គៀសខ្លួនបែកខ្ញែកទៅទីកន្លែងផ្សេងៗគ្នា បានវិលត្រលប់មកជួបជុំគ្នាវិញ ប៉ុន្តែទទួលបាននូវការកំណត់អត្តសញ្ញាណ និងបែងចែកក្រុមប្រជាជនរៀងខ្លួន។ ការជួបជុំនៃអ្នកភូមិទី៨នាគ្រានេះ គឺគ្មានអ្វីក្រៅតែពីការផ្លាស់ប្តូរពីមិត្តទៅជាសត្រូវ ពីបងប្អូនទៅជាមិត្តរួមបដិវត្តន៍ និងពីអ្នកស្គាល់គ្នាទៅជាអ្នកមិនដែលស្គាល់គ្នានោះទេ។

ខាងក្រោមនេះ គឺជាការចងក្រងនូវសាច់រឿង និងបទពិសោធន៍ដែលមិនអាចបំភ្លេចបានរបស់ប្រជាជន ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម និងបន្តរស់នៅក្នុងភូមិទី៨ ៖

### ប្រជាជនចាស់ (ហៅថាពួកប្រជាជន៧០) ដែលទទួលបានការទុកចិត្តពីខ្មែរក្រហម

ប្រធានកងចល័តនារីខ្មែរក្រហម



ឡុង គឹមស្រ៊ាង ប្រជាជន៧០ និងជាប្រធានកងចល័តនារីខ្មែរក្រហម។
(ស៊ាង ចិន្តា/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡុង គឹមស្រ៊ាង[3] អតីតប្រជាជន៧០ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរំឭកអំពីបទពិសោធន៍ជាប្រធានកងរយក្នុងរបបខ្មែរក្រហមថា៖

ខ្ញុំឈ្មោះ ឡុង គឹមស្រ៊ាង អាយុ៦៤ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ នៅវ័យកុមារ ខ្ញុំរៀននៅសាលាបឋមសិក្សាវត្តគ្រួអ៊្លុកបានត្រឹមថ្នាក់ទី១០ចាស់ ជាមួយមិត្តរបស់ខ្ញុំឈ្មោះ ម៉ៅ វណ្ណា។ ខ្ញុំឃើញអ្នកភូមិជាច្រើន បានចូលរួមបាតុកម្មដង្ហែទៅទីរួមខេត្តកំពង់ចាម បន្ទាប់ពីរដ្ឋប្រហារនៅឆ្នាំ១៩៧០។

នៅចុងឆ្នាំ១៩៧០ កងទ័ពខ្មែរក្រហម បានចាប់ផ្ដើមចូលមកក្នុងភូមិជាបណ្ដើរៗ និងប្រយុទ្ធគ្នាជាមួយទាហាន លន់ នល់។ ពេលនោះ ខ្ញុំរត់គៀសខ្លួនទៅរស់នៅភូមិមហាលាភ។ នៅឆ្នាំ១៩៧៥ ខ្ញុំវិលត្រលប់មកភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៦ ខ្ញុំចូលធ្វើការនៅក្នុងកងចល័តនារី និងកងចុងភៅរោងបាយរួមស្ថិតនៅកណ្ដាលកោះសូទិន។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានដាក់ឱ្យធ្វើជាប្រធានកងរយ ដែលមានមនុស្សចំនួន ៩៧នាក់។ កងចល័តរយ គឺមានទិសដៅធ្វើការងារនៅការដ្ឋានផ្ទ័ត្រ ដែលស្ថិតនៅខាងអូររាំងឪ។ នៅឆ្នាំ១៩៧៧ដដែល ខ្ញុំទទួលបានបទបញ្ជាឱ្យស្រង់ឈ្មោះសមមិត្តចំនួន ៣៤នាក់ ដែលកំពុងធ្វើការនៅក្នុងកងចល័តរយនេះ។ ខ្ញុំគ្មានជម្រើសអ្វីឡើយ ហើយខ្ញុំបានដើរស្រង់ឈ្មោះមិត្ត ៣៤នាក់នោះ និងប្រគល់ដល់ប្រធានក្ដាប់ធំ គឺសមមិត្ត ជុន។ នៅថ្ងៃបន្ទាប់ ខ្ញុំដឹងថាឈ្មោះមិត្តទាំង ៣៤នាក់នោះ ត្រូវបានសម្លាប់នៅទីវាលក្រោយភូមិ ដែលជិតទីតាំងសម្លាប់នោះ គឺមានគុកមួយហៅថា គុកចាន់អណ្ដែត។ នៅក្នុងឆ្នាំនោះដដែល ខ្ញុំត្រូវបានបញ្ជាឱ្យបន្តស្រង់ឈ្មោះប្រជាជនថ្មី ដែលនៅសេសសល់ក្នុងកងចល័តរយ។ ខ្ញុំស្រង់បានឈ្មោះត្រឹមតែ ១១នាក់តែប៉ុណ្ណោះ។ពេលនោះ ខ្ញុំមិនដឹងថាសមមិត្ត វណ្ណា គឺជាប្រជាជនថ្មីដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញនោះឡើយ ទើបខ្ញុំមិនបានដាក់ឈ្មោះរបស់ សមមិត្ត វណ្ណា នៅក្នុងបញ្ជីសម្លាប់។ ខ្ញុំដឹងត្រឹមថា វណ្ណា ក៏ជាប្រជាជនមូលដ្ឋានដូចខ្ញុំដែរ។ នៅចុងឆ្នាំ១៩៧៨ ទើបខ្ញុំឮដំណឹងថាឈប់ឱ្យសម្លាប់មនុស្ស និងឱ្យវិលត្រលប់មកភូមិវិញ។

កងនេសាទខ្មែរក្រហម

លឹម អេង[4] អាយុ ៧៧ឆ្នាំ រស់នៅ និងមានស្រុកកំណើតនៅក្នុងភូមិទី៩ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ លឹម អេង រៀបការប្រពន្ធឈ្មោះ សេត ឡាង និងមានកូនចំនួន ៦នាក់។ គាត់គឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីសរុបចំនួន ៥នាក់។ នៅវ័យកុមារ អេង ចូលរៀននៅសាលាបឋមសិក្សាវត្តចុងកោះសូទិន និងបន្តការសិក្សានៅទីរួមខេត្តកំពង់ចាម។ អេង ក៏បានរៀននៅសាលាឯក

---

[3] ឡុង គឹមស្រ៊ាង «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

[4] លឹម អេង «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជនមួយដើម្បីត្រៀមប្រឡងចូលថ្នាក់ទី៣សង្គមចាស់។ ក្រោយមកទៀត អេង សម្រេចចិត្តត្រលប់ទៅរៀននៅស៊ីធរកណ្ដាល ខេត្តព្រៃវែង វិញ ពីព្រោះតែមានឪពុកមារស់នៅទីនោះ។ អំឡុងពេលដែលកំពុងស្នាក់នៅ និងរៀនសូត្រនៅស៊ី ធរកណ្ដាល អេង បានឮដំណឹងថាមានរដ្ឋប្រហារទម្លាក់សម្ដេចឪ។ បន្ទាប់មក បងប្អូនបានបបួល អេង ទៅចូលធ្វើជាទាហាន លន់ នល់ នៅទីក្រុងភ្នំពេញ។ អេង មិនទៅនោះទេ។មិនយូរប៉ុន្មានបាតុកម្មបានផ្ទុះឡើង និងដង្ហែទៅទីរួមខេត្តកំពង់ចាម។ ដោយឃើញស្ថានភាពមិនស្រួល អេង បានវិលត្រលប់មករស់នៅភូមិជួបជុំជាមួយគ្រួសារវិញ។ នៅឆ្នាំ១៩៧១ កងទ័ពខ្មែរក្រហម ចូលមកដល់ក្នុងភូមិ និងស្នាក់អាស្រ័យនៅក្រោម និងក្រោយផ្ទះរបស់អ្នកភូមិ។ ពេលនោះ គឺជាវេលានៃការផ្ទុះអាវុធរវាងទាហាន លន់ នល់ ដែលឈរជើងនៅត្រើយម្ខាង និងនៅទីរួមខេត្តកំពង់ចាម ជាមួយកងទ័ពខ្មែរក្រហម ដែលឈរជើងនៅភូមិនានានៅកោះសូទិន។ ភូមិទី៩នៃឃុំកោះសូទិន ទទួលរងការផ្លោងគ្រាប់កាំភ្លើងធំ ដែលបានបាញ់ចេញពីភ្នំស្រីភ្នំប្រុសយ៉ាងខ្លាំង។ នៅក្នុងឆ្នាំ១៩៧១ដដែល គ្រួសាររបស់ អេង បានរត់គៀសខ្លួនចេញពីភូមិទៅរស់នៅជាមួយបងប្អូននៅភូមិជ្រៃកឃ្មុំ ឃុំជ្រៃកឃ្មុំ ស្រុកស៊ីធរកណ្ដាល ដែលជាតំបន់រំដោះខ្មែរក្រហម។ បន្ទាប់ពីបានទៅដល់ អេង បានស្ម័គ្រចិត្តចូលធ្វើជាគ្រូបង្រៀនមូលដ្ឋាន។ អេង ត្រូវបានបញ្ជូនទៅ

រៀនវគ្គបណ្តុះបណ្តាលអស់រយៈពេល ៣ខែ។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលបានបញ្ចប់ អេង បានបង្រៀនថ្នាក់ទី៣នៅសាលាបឋមសិក្សាស្វាយទាប ដែលមានមិត្ត ឈាន គឺជានាយកសាលា។ នៅឆ្នាំ១៩៧៣ អេង បានរៀបការប្រពន្ធឈ្មោះ សេត ឡាង និងទៅរស់នៅជាមួយគ្រួសារខាងប្រពន្ធ។ អេង បានឈប់បង្រៀនដោយសារតែផ្ទះ ខាងប្រពន្ធមានចម្ងាយនៅឆ្ងាយពីកន្លែងបង្រៀនពេក។ ក្រោយមកទៀត អេង ស្ម័គ្រចិត្ត



លឹម អេង ប្រជាជន៧០ និងកងនេសាទខ្មែរក្រហម រស់នៅភូមិទី៨ ឃុំ/ស្រុកកោះសូទិន។
(ស៊ាង ចិន្តា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចូលធ្វើជាពេទ្យ និងត្រូវបានបញ្ជូនទៅរៀនវគ្គបណ្តុះបណ្តាលរយៈពេល ៣ខែ ដើម្បីរៀនអំពីការចាក់ថ្នាំ ផ្សំថ្នាំ និងពិនិត្យមើលអាការជំងឺ។ បន្ទាប់ពីរៀនចប់ អេង ត្រូវបានចាត់តាំងឱ្យធ្វើជាពេទ្យប្រចាំភូមិ ដើម្បីពិនិត្យ និងព្យាបាលប្រជាជនមូលដ្ឋាន។ នៅចុងឆ្នាំ១៩៧៣ មេភូមិ ដែលមិនបានចាំឈ្មោះ បានប្រាប់ដំណឹងជ្រើសរើសពេទ្យជំនាញវះកាត់។ នៅពេលនោះ បងថ្លៃរបស់អេង ដែលជាពេទ្យមូលដ្ឋានផងដែរនោះ បានស្ម័គ្រចិត្តចូលរៀនជំនាញពេទ្យវះកាត់ និងត្រូវបានបញ្ជូនទៅរៀន ប៉ុន្តែបងថ្លៃរបស់អេង មិនដែលវិលត្រលប់មកភូមិវិញនោះទេ។ នៅឆ្នាំ១៩៧៤ អេង បាននាំប្រពន្ធ និងកូនមករស់នៅភូមិទី៩ ដែលជាភូមិកំណើត វិញ។ នៅពេលដែលត្រៀមឆ្លងទន្លេត្រលប់មកភូមិវិញ ទាហានលន់ នល់ បានបើកចុះឡើងដើម្បីបាញ់បើកផ្លូវ

ឡើងទៅកំពង់ចាម។ អេង និងប្រពន្ធកូន បានឈប់ស្នាក់នៅម្តុំកោះចិនមួយយប់សិន។ នៅពេលដែលមានសភាពស្ងប់ស្ងាត់វិលត្រលប់មកវិញ អេង និងគ្រួសារ ជួលទូកជិះឆ្លងទន្លេមករស់នៅភូមិវិញ។

នៅឆ្នាំ១៩៧៥ អេង និងគ្រួសារ រស់នៅក្នុងភូមិទី៩។ នៅឆ្នាំ១៩៧៦ គឺជាពេលដែល អេង និងអ្នកភូមិផ្សេងទៀតចាប់ផ្តើមហូបបាយរួម។ អេង ត្រូវបានចាត់តាំងឱ្យធ្វើការនៅកងនេសាទភូមិ ដែលមានគ្នាចំនួន ១០នាក់ សម្រាប់រកត្រីមកឱ្យរោងបាយ។ កងនេសាទមានខ្មែរ-អ៊ីស្លាម រួមមាន មិត្តលាស់ មិត្តកូប និងមិត្តម៉ាន ដែលជាអ្នកជំនាញជួសមង ឬដោះមងដែលជាប់នៅបាតទន្លេ។ ប្រធានកងនេសាទ គឺមិត្ត វ៉ែង ថៃ។ កងនេសាទរបស់អេង គឺធ្វើការចាប់ពីពាក់កណ្តាលយប់ ដោយបានរាយមងនៅកណ្តាលទន្លេ និងចូលមកសម្រាកវិញ។ រហូតដល់ម៉ោង ៦ព្រឹក កងនេសាទ បានចែវទូកទៅលើកមងជាប់មកសុទ្ធតែត្រី ដូចជា ត្រីគល់រាំង ត្រីក្អែក និងត្រីព្រួល ជាដើម។ បន្ទាប់មក កងដឹកជញ្ជូន បានដឹកត្រីដែលរកបានទៅរោងបាយរួម ដើម្បីធ្វើម្ហូបឱ្យអ្នកភូមិ។ នៅឆ្នាំ១៩៧៧ អេង ឃើញមានកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីក្មេងចាស់ចូលមកដល់ក្នុងភូមិ។ កងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតី បានធ្វើការចាប់ចង ធ្វើទារុណកម្ម និងសម្លាប់អ្នកមូលដ្ឋានចាស់យ៉ាងច្រើន។[៧] អេង មិនហ៊ានសូម្បីតែមើលមុខកងទ័ពខ្មែរក្រហមផង។ អេង បន្តធ្វើការនៅកងនេសាទ និងពេលខ្លះមកលេងប្រពន្ធ និងកូននៅផ្ទះ។ ក្រោយមក មិត្តលាស់ មិត្តកូប និងមិត្តម៉ាន នៅកងនេសាទភូមិ ត្រូវបានចាប់ខ្លួនយកទៅសម្លាប់។ អេង មិនដឹងថាពួកគេត្រូវបានសម្លាប់នៅកន្លែងណាទេ។ អេង ធ្វើការនៅកងនេសាទរហូតដល់កងទ័ពរណសិរ្សចូលមករំដោះប្រជាជនចេញពីខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩។

អេង និងគ្រួសាររួចផុតជីវិតពីរបបខ្មែរក្រហម និងធ្វើស្រែចំការដើម្បីចិញ្ចឹមជីវិតរហូតដល់ពេលបច្ចុប្បន្ននេះ។

កងចល័តនារីខ្មែរក្រហម

**ហុក ណៃវេង**[5] ភេទស្រី រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ណៃវេង រៀបការប្តីឈ្មោះ អាន រី និងមានកូនចំនួន ៥នាក់។ គាត់ បានរៀននៅសាលាបឋមសិក្សាវត្តចុងកោះ



ហុក ណៃវេង ប្រជាជន៧០ និងកងចល័តនារីយកណ្តាល រស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន។ ស៊ាង ចិន្តា/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

រហូតដល់ថ្នាក់ទី១០ចាស់។ ដោយសារតែមានជីវិតក្រីក្រ ណៃវេង បានបោះបង់ការសិក្សាមកជួយការងារឪពុកម្តាយនៅផ្ទះវិញ។ បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០ បាតុកម្មបានផ្ទុះឡើងដោយមានការចូលរួមយ៉ាងសកម្មពីអ្នកភូមិ។ នៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ សង្គ្រាមរវាងទាហាន លន់ នល់ និងកង

---

[5] ហុក ណៃវេង «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ទ័ពខ្មែរក្រហម បានចាប់ផ្តើម។ នៅពេលនោះ ណៃវេង រត់គៀសខ្លួនទៅកោះចិន និងបានស្នាក់នៅទីនោះ ដោយសង្ឃឹមថាស្ថានភាពបានស្ងប់ស្ងាត់ទៅវិញ។ ចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ កងទ័ពខ្មែរក្រហម បានបើកការវាយប្រហារកាន់តែខ្លាំងឡើងៗ ដើម្បីកាន់កាប់ទីរួមខេត្តកំពង់ចាម។ នៅពេលនោះ ទាហាន លន់ នល់ ដែលបើកទូកតាមបណ្តោយទន្លេ តែងតែបាញ់រះមកលើតំបន់រំដោះខ្មែរក្រហម។ ណៃវេង រត់ទៅពួនក្នុងរណ្តៅត្រង់សេ។ នៅចុងឆ្នាំ១៩៧៤ ណៃវេង បានវិលត្រលប់មកភូមិវិញ និងត្រូវបានមេភូមិដាក់ឱ្យធ្វើការនៅក្នុងកងប្រវាស់ដៃ ដើម្បីធ្វើស្រែ។ ចន្លោះពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ប្រជាជនរស់នៅតំបន់រំដោះខ្មែរក្រហមត្រូវបានរៀបចំឱ្យទៅជា កងប្រវាស់ដៃ ដែលមានគ្នាពី ១០ទៅ ៣០គ្រួសារ ក្នុងមួយក្រុម។

ណៃវេង រៀបការប្តីឈ្មោះ អាន រី នៅឆ្នាំ១៩៧៦ គឺបន្ទាប់ពីមានការបង្កើតសហករណ៍កម្រិតទាបទៅកម្រិតខ្ពស់។ ការរៀបការត្រូវបានរៀបចំដោយអង្គការ និងមានចំនួនចាប់ពី ៣ទៅ១០គូ ក្នុងពិធីរៀបការតូច ហើយចាប់ពី ៣០ទៅ៥០គូ ឬរហូតដល់ជាង១០០គូ ក្នុងពិធីរៀបការធំ។ បន្ទាប់មក គ្រួសាររបស់ ណៃវេង ត្រូវបានបែកចែកទៅធ្វើការងារក្នុងកងរៀងៗខ្លួន ដូចជា កងទី១) កងទារកដ្ឋានគឺសម្រាប់កូនរបស់ណៃវេង ដើម្បីឱ្យយាយៗមើលថែរក្សា នៅពេលដែលឪពុកម្តាយចេញទៅធ្វើការងារ។ កងទី២) គឺកងកុមារ សម្រាប់ប្អូនប្រុសស្រីរបស់ណៃវេង ដើម្បីដើរប្រមូលលាមកសត្វ និងកាត់ទន្ទ្រានខេត្តយកទៅធ្វើជីដាក់ស្រែ។ កងទី៣) គឺកងចល័តបុរសសម្រាប់ប្អូនប្រុសរបស់ណៃវេង ដែលត្រូវបានចាត់តាំងធ្វើការងារនៅទិសដៅការដ្ឋានផ្ទ័ត្រ ដោយចាត់ឱ្យ ជីកដី លើកដី និងភ្ជួររាស់។ ជាអកុសល ប្អូនប្រុសរបស់គាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចាប់យកទៅសម្លាប់។ កងទី៤ គឺកងចល័តនារីវ័យកណ្តាល សម្រាប់គាត់ និងប្តីដែលត្រូវបានចាត់តាំងធ្វើការងារនៅទិសដៅការដ្ឋានកោះសូទិន ដោយចាត់ឱ្យ ដាំដុះ ដំណាំ ភ្ជួររាស់ ដកស្ទូង និងច្រូតកាត់។ ណៃវេង និងប្តី ត្រូវធ្វើការងារពីព្រលឹមទល់ព្រលប់។ កងទី៥ គឺកងវ័យជរាសម្រាប់ឪពុកម្តាយចាស់ៗដើម្បីជួលមើលថែរក្សាកូនរបស់អ្នកភូមិដែលត្រូវទៅធ្វើការងារនៅតាមការដ្ឋាន។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រងភូមិ និងចាប់ផ្តើមការចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន និងរឹតត្បិតរបបអាហារ។ណៃវេង និងប្តី ត្រូវខ្មែរក្រហមដាក់ការងារឱ្យធ្វើកាន់តែច្រើនឡើង និងគ្មានពេលសម្រាកគ្រប់គ្រាន់ឡើយ។ នៅឆ្នាំ១៩៧៨ ភូមិរបស់គាត់ ត្រូវបានទឹកជំនន់លិច និងគ្មានដីដើម្បីធ្វើស្រែ និងដាំដំណាំទៀតឡើយ។ បើទោះបីជាទឹកលិចអស់ក៏ដោយ ខ្មែរក្រហមនៅតែបន្តបង្ខំឱ្យអ្នកភូមិធ្វើការនៅតាមផ្ទះរៀងខ្លួនអស់រយៈពេល ១ខែ។ ជាញឹកញាប់ កងឈ្លបខ្មែរក្រហម ត្រូវបានបញ្ជូនមកដើម្បីតាមដានអ្នកភូមិ ថាតើអ្នកភូមិណាមិនធ្វើការឬនិយាយអ្វីខ្លះ។ ក្នុងរយៈពេលទឹកជំនន់លិចជាង ១ខែនេះ ណៃវេង មានពេលសម្រាកនៅលើផ្ទះ និងអាចទៅហូបបាយនៅរោងបាយរួមដែលស្ថិតនៅទីទួលមួយនៅក្នុងភូមិ។ បើទោះបីជាមិនទៅធ្វើការងារនៅតាមការដ្ឋានក៏ដោយ គាត់នៅតែបន្តធ្វើគ្រាប់ពោត និងមិនហ៊ានឈប់សម្រាកច្រើនឡើយ ពីព្រោះកងឈ្លបខ្មែរក្រហមតែងតែចៃវទូក

ស៊ើបការណ៍នៅក្រោមផ្ទះរបស់អ្នកភូមិ។ ខ្មែរក្រហមនៅតែបង្ខំឱ្យប្រជាជនធ្វើការងារ បង្អត់អាហារ និងសម្លាប់ប្រជាជនទម្លាក់ចោលចូលក្នុងទឹកទន្លេ ដើម្បីបំបិទភស្តុតាង។

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមកដល់ ហើយជួយរំដោះប្រជាជនចេញពីក្រុមខ្មែរក្រហម។ ណៃរេង និងគ្រួសារ រួចផុតពីសេចក្តីស្លាប់ ប៉ុន្តែបានបាត់បង់ប្អូនប្រុសម្នាក់នៅក្នុងរបបខ្មែរក្រហម។

## ប្រជាជនកណ្តាល (ហៅថា ពួកប្រជាជន៧៣)

បទពិសោធន៍កងចល័តវ័យកណ្តាល និងការត្រៀមយកប្រជាជនកណ្តាលទៅសម្លាប់ចោល

អាន រី[6] ប្រជាជនកណ្តាល(ប្រជាជន៧៣) និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរំឭកអំពីបទពិសោធន៍របស់គាត់ ថា៖

ខ្ញុំឈ្មោះ អាន រី រស់នៅភូមិទី៨ ឃុំ/ស្រុកកោះសូទិន ខេត្តកំពង់ចាម។ នៅពីក្មេង ខ្ញុំរៀននៅសាលាបឋម សិក្សាកោះប្រាក់។ ខ្ញុំរៀនបានថ្នាក់ទី៧សង្គមចាស់។ នៅឆ្នាំ១៩៧១ សង្គ្រាមបានផ្ទុះឡើងកាន់តែ



អាន រី ប្រជាជនកណ្តាល (ប្រជាជន៧៣) និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រំឭកអំពីបទពិសោធន៍របស់ខ្លួន និងគ្រាដែលខ្មែរក្រហមមកពីភូមិភាគនិរតីត្រៀមចាប់ប្រជាជន៧៣ យកទៅសម្លាប់ចោល។
(ស៊ាង ចិន្តា/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

---

[6] អាន រី «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ខ្លាំង បណ្ដាលឱ្យឆេះផ្ទះសម្បែងរបស់អ្នកភូមិ។ នៅឆ្នាំ១៩៧២ ខ្ញុំ និងគ្រួសាររត់ភៀសខ្លួនទៅខាងខេត្តកំពង់ចាម ហើយពេលកងទ័ពខ្មែរក្រហម ចូលមកដល់ខេត្តកំពង់ចាមនៅឆ្នាំ១៩៧៣ ខ្ញុំ និងគ្រួសារត្រូវបានជម្លៀសមកខាងកោះសូទិនវិញ។

នៅឆ្នាំ១៩៧៥ ខ្ញុំរៀបការប្រពន្ធ។ ខ្ញុំធ្វើស្រែនៅក្រុមប្រវាស់ដៃរយៈពេល ៥ខែ ទើបមានការបង្កើតសហករណ៍។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវខ្មែរក្រហមឱ្យទៅធ្វើការនៅក្នុងកងចល័តបុរស ដោយឱ្យលើកទំនប់។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមកពីភូមិភាគនិរតីចូលមកដល់ភូមិ និងការដ្ឋានលើកទំនប់។ ពេលនោះ ប្រជាជន៧៥ ដែលនៅសេសសល់ក្នុងភូមិ និងតាមការដ្ឋាន ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់យ៉ាងច្រើន។ ខ្ញុំក៏ជាប្រជាជនម្នាក់ស្ថិតនៅក្នុងការកំណត់ចាប់យកទៅសម្លាប់ដែរ ព្រោះខ្ញុំគឺជាប្រជាជនកណ្ដាល ដែលត្រូវបានរំដោះនៅឆ្នាំ១៩៧៣ ប៉ុន្តែសំណាងល្អ ខ្ញុំអាចរួចផុតពីសេចក្ដីស្លាប់ និងវិលត្រលប់មករស់នៅភូមិវិញ រហូតដល់បច្ចុប្បន្ននេះ។

កងចល័តនារីវ័យកណ្ដាល



ស៊ឹង គឹមស្រ៊ុន អាយុ៧២ឆ្នាំ ប្រជាជនកណ្ដាល (ប្រជាជន៧៣) និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅក្នុងភូមិទី៨ ឃុំ/ស្រុកកោះសូទិន ខេត្តកំពង់ចាម។
(ស៊ាង ចិន្តា/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស៊ឹង គឹមស្រ៊ុន[7] អាយុ ៧២ឆ្នាំ ប្រជាជនកណ្តាល(ប្រជាជន៧៣) និង ជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅក្នុងភូមិទី៨ ឃុំ/ស្រុកកោះសូទិន ខេត្តកំពង់ចាម បានរៀបរាប់ថា៖

ខ្ញុំមានមុខរបរជាកសិករធ្វើស្រែចំការ ហើយបានរៀបការប្តីឈ្មោះ ស៊ុន សឿន។ ខ្ញុំកើតនៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ កៅ ឡេង និងម្តាយឈ្មោះ ពិន ស្រ៊ី។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីចំនួន ៧នាក់។ នៅវ័យកុមារ ខ្ញុំបានទៅរៀននៅសាលាបឋមសិក្សាគ្រូអ៊ុក។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី ១០ចាស់ ហើយក្រោយមកឈប់រៀននៅអាយុ ១៣ឆ្នាំ ដើម្បីជួយការងារឪពុកម្តាយនៅផ្ទះ និងមើលថែរក្សាប្អូនៗ។ នៅអាយុ ១៥ឆ្នាំ ខ្ញុំរៀបការប្តី ដែលធ្វើជាប៉ូលីស។ ខ្ញុំទៅរស់នៅជាមួយប្តីនៅជីហែរ។ មួយរយៈក្រោយមក ប្តីខ្ញុំ និងខ្ញុំ ត្រូវបានផ្លាស់ទៅត្រពាំងថ្លុង។ ក្រោយពេលខ្ញុំបង្កើតកូនបានម្នាក់ ខ្ញុំក៏វិលត្រលប់មករស់នៅជីហែរវិញ។ នៅដើមឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ មានបាតុកម្មផ្ទុះឡើង និងដង្ហែទៅទីរួមខេត្តកំពង់ចាម។ អ្នកភូមិជាច្រើនបានចូលរួមបាតុកម្មនោះ។ ខ្ញុំបានមករស់នៅផ្ទះជាមួយម្តាយរបស់ខ្ញុំនៅកោះសូទិន។ នៅឆ្នាំ១៩៧១ ខ្ញុំឃើញកងទ័ពខ្មែរក្រហមចូលមកដល់ភូមិ។ ប្តីរបស់ខ្ញុំត្រូវបានចាត់តាំងទៅធ្វើការងារកេស្តុការនៅខេត្តព្រៃវែង។ នៅពេលនោះ ប្តីរបស់ខ្ញុំមិនដែលមកលេងផ្ទះនៅកោះសូទិនទេ។ នៅឆ្នាំ១៩៧៣ ភូមិទី៨ គឺជាសមរភូមិក្តៅរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។ ទាហាន លន់ នល់ បានទម្លាក់គ្រាប់បែកជាច្រើនទៅលើទីតាំងដែលមានកងទ័ពខ្មែរក្រហម។ នៅឆ្នាំ១៩៧៤ ខ្ញុំបានរត់គៀសខ្លួនជាមួយកូនទៅរស់នៅជាមួយប្តីដែលទើបតែត្រូវបានផ្លាស់មកនៅអូររាំងឪ។

នៅឆ្នាំ១៩៧៥ ខ្ញុំទទួលបានដំណឹងថា ម្តាយរបស់ខ្ញុំដែលរស់នៅកោះសូទិនបានស្លាប់។ ខ្ញុំបាននាំកូន និងប្អូនតូចរបស់ខ្ញុំត្រលប់មកភូមិវិញ ដោយបានដើរពីអូររាំងឪរហូតមកដល់កោះចិន និងឆ្លងទៅខាងកោះសូទិននៅព្រឹកបន្ទាប់។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើការងារនៅកងចល័តវ័យកណ្តាល ដោយបានដើរទៅរែកដី ជីកប្រឡាយ ស្ទូងស្រូវ កាត់ថ្នាំ និងកាច់ពោត។ ខ្ញុំត្រូវក្រោកនៅម៉ោង ៤ព្រឹកដើម្បីតម្រង់ជួរ និងចាប់ផ្តើមធ្វើការនៅម៉ោង ៦ ដល់១១ព្រឹក និងម៉ោង ១រសៀលដល់ ៥ល្ងាច។ ខ្ញុំទទួលបានរបបអាហារត្រឹមតែបបរាវប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រង និងចាប់ផ្តើមចាប់ខ្លួនប្រធានកង មេភូមិ និងប្រជាជន១៧មេសា ដើម្បីយកទៅសម្លាប់ចោល។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានដាក់ជាប្រជាជនត្រៀម គឺជាក្រុមប្រជាជនដែលខ្មែរក្រហមយកទៅសម្លាប់នាពេលឆាប់ៗខាងមុខបន្ទាប់ទៀត។ ប្រជាជនចាស់ និងប្រជាជន១៧មេសាជាច្រើន ត្រូវបានចាប់ខ្លួនយកទៅសម្លាប់នាពេលនោះ។ ខ្ញុំធ្វើការនៅក្នុងកងចល័តវ័យកណ្តាល រហូតដល់ពេលដែលកងទ័ពវៀតណាម

---

[7] ស៊ឹង គឹមស្រ៊ុន «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ចូលមករំដោះ។ ខ្ញុំពិតជាមានសំណាងបានរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម និងប្រកបរបររស់នៅជាកសិកររហូតដល់ពេលសព្វថ្ងៃនេះ។

## ប្រជាជនថ្មី (ហៅថាពួកប្រជាជន៧៥)

មិត្តកុមារភាពអាចត្រឹមជួយសង្គ្រោះជីវិតខ្ញុំ ប៉ុន្តែមិនអាចជួយជីវិតគ្រួសាររបស់ខ្ញុំឡើយ

ម៉ៅវណ្ណា[8] ប្រជាជនថ្មីមកពីទីក្រុងភ្នំពេញ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានបាត់បង់ឪពុកម្តាយ និងបងប្អូនប្រុសស្រីចំនួន ៣នាក់ បានចែករំលែកពីរឿងរ៉ាវជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមថា៖

ខ្ញុំឈ្មោះ ម៉ៅ វណ្ណា កើតនៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ លាងគ្រី គឺជាគ្រូបង្រៀននៅវិទ្យាល័យជម្ពូវ័ន និងម្តាយឈ្មោះ ម៉ៅ សុផល គឺជាមេផ្ទះ។ ឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ និងទម្លាក់ចោលចូលក្នុងទន្លេ សំណាងល្អតែរូបខ្ញុំម្នាក់ទេដែលអាចរួចផុតពីការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាចុងកោះរហូតដល់ថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំស្នាក់នៅជាមួយជីដូននៅក្នុងភូមិចំណែកឯឪពុកម្តាយ និងបងប្អូនផ្សេងទៀតរបស់ខ្ញុំរស់នៅទីក្រុងភ្នំពេញ។ ប៉ុន្មានខែបន្ទាប់ពីមានរដ្ឋប្រហារនៅឆ្នាំ១៩៧០ មានអ្នកភូមិចូលរួមដង្ហែបាតុកម្មទៅទីរួមខេត្តកំពង់ចាមច្រើនកុះករ។ ក្រោយមកទៀត កងទ័ពខ្មែរក្រហម បានចូលមកដល់ និងស្នាក់នៅក្រោមផ្ទះរបស់អ្នកភូមិ។ នៅចុងឆ្នាំ១៩៧០ និងដើមឆ្នាំ១៩៧១ សង្គ្រាមរវាង ទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម បានផ្ទុះឡើងជាច្រើនសមរភូមិនៅកោះសូទិន។ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ទាហានលន់ នល់ បើកការវាយប្រហារទៅលើកងទ័ពខ្មែរក្រហមដែលឈរជើងនៅកោះសូទិនកាន់តែខ្លាំងឡើង។ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាព ឪពុកម្តាយបានយកខ្ញុំទៅរស់នៅជាមួយគាត់នៅទីក្រុងភ្នំពេញវិញ។ នៅពេលនោះ ខ្ញុំបានបន្តរៀននៅសាលាបឋមសិក្សា និងវិទ្យាល័យជម្ពូវ័ន រហូតដល់ថ្នាក់ទី៤។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញ ត្រូវបានវាយបែកដោយកងទ័ពខ្មែរក្រហម។ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ឪពុកម្តាយរបស់ខ្ញុំ សម្រេចចិត្តនាំកូនៗមកភូមិកំណើតនៅកោះសូទិន ដើម្បីរស់នៅជាមួយជីដូនវិញ។ បន្ទាប់ពីមកដល់ភូមិ គ្រួសាររបស់ខ្ញុំត្រូវបានប្រជាជនមូលដ្ឋានចាត់ទុកថាជាប្រជាជន ១៧មេសា និងមានប្រវត្តិធ្លាប់ជាគ្រូបង្រៀននៅរបបចាស់។ បន្ទាប់មក ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ ត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានភូមិតាណុង ដែលជាកន្លែងប្រមូលផ្តុំប្រជាជន ដែលជាប់និន្នាការក្នុងរបប លន់ នល់ ដើម្បីលត់ដំខ្លួន។ នៅពេលនោះ ខ្ញុំមិនបានទៅ

---

[8] ម៉ៅ វណ្ណា «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាមួយឪពុកម្តាយ និងបងប្អូនទេ ពីព្រោះដីដូនរបស់ខ្ញុំបានប្រាប់មេភូមិថា ខ្ញុំគឺជាអ្នកមូលដ្ឋានចាស់។ នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើការនៅកងចល័តនារី ដើម្បីធ្វើស្រែ ជីកដី និងលើកទំនប់។[9] នៅឆ្នាំ១៩៧៧ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ទីធ្វើការ ហើយកន្លែងនោះគឺជាកន្លែងដែលខ្ញុំស្ទើរតែត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោល និងជាកន្លែងដែលខ្ញុំឃើញផ្ទាល់ភ្នែកនូវទុក្ខវេទនារបស់គ្រួសាររបស់ខ្ញុំនៅពេលនោះ។

កងចល័តនារីរបស់ខ្ញុំ គឺមានមិត្តនារីទាំងអស់ចំនួន ៩៧នាក់ ត្រូវទៅជីកលើកដី និងធ្វើស្រែគ្មានពេលសម្រាក និងគ្មានអាហារហូបចុកគ្រប់គ្រាន់ទេ។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកដល់ និងចាប់ផ្តើមចាប់កម្មាភិបាលមូលដ្ឋាន និងប្រធានកងយកទៅសម្លាប់ចោល។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ក៏ចាប់ផ្តើមស្រាវជ្រាវប្រវត្តិប្រជាជន១៧មេសា។ នៅពេលនោះ កងចល័តនារី មានគ្នានៅសេសសល់ ប្រហែល ៦០នាក់ ហើយនៅយប់មួយ ប្រធានកងចល័តនារីឈ្មោះ ស្រ៊ាង បានដើរស្រង់ឈ្មោះអ្នកដែលមានប្រវត្តិជា ប្រជាជន១៧មេសា។ ខ្ញុំដឹងថា ប្រជាជន១៧មេសានៅពេលនោះ គឺត្រូវបានស្រង់ឈ្មោះបានចំនួន ១៣នាក់រួមទាំងឈ្មោះរបស់ខ្ញុំដែរ។ ប៉ុន្តែ មិត្តនារី ស្រ៊ាង ដែលជា



ម៉ៅ វណ្ណា អាយុ៦៨ឆ្នាំ ប្រជាជនថ្មីមកពីទីក្រុងភ្នំពេញ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទស្សនកិច្ចមកកាន់ព្រះរាជបណ្ណាល័យហ្លួងម៉ែ នៅទីក្រុងភ្នំពេញ។
(លី ដេវីត/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

---

(9) មជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកសារលេខD00591, «រោងផែនការ៤ឆ្នាំ កសាងសង្គមនិយម គ្រប់ផ្នែករបស់បក្ស ឆ្នាំ១៩៧៧-១៩៨០», បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

អតីតមិត្តភក្តិរៀនថ្នាក់ទី១១ នៅសាលាបឋមសិក្សាចុងកោះជាមួយគ្នា ហើយបានស្គាល់ខ្ញុំ និងមិនដឹងថាខ្ញុំជាប្រជាជនថ្មីនោះឡើយ។ ដូច្នេះហើយ មិត្ត ស្រ៊ាង មិនបានហៅឈ្មោះរបស់ខ្ញុំរៀបចំបាយពោត ដើម្បីយកទៅសម្លាប់ចោលនោះទេ។ ចំណែកឯ មិត្តនារីទាំង ១២នាក់ផ្សេងទៀត ត្រូវបាន មិត្តស្រ៊ាង ប្រាប់ឱ្យរៀបចំបាយពោត និងយកទៅតាមគាត់។ ខ្មែរក្រហម បានបណ្តើរនារីទាំង ១២នាក់ ដែលត្រូវបានស្រង់ឈ្មោះ និងប្រាប់ឱ្យរៀបចំបាយយកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃ។ នៅឆ្នាំ១៩៧៨ ខ្ញុំទទួលបានដំណឹងថាឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ និងទម្លាក់ចោលក្នុងទឹកទន្លេ ពីព្រោះជាប្រជាជន១៧មេសា។

### ជីវិតនៃការរត់គៀសខ្លួនចេញពីសង្គ្រាម និងការទទួលបានអត្តសញ្ញាណជាប្រជាជនថ្មី

ធី វាសនា[10]មកពីទីក្រុងភ្នំពេញ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានបាត់បង់សមាជិកគ្រួសារស្ទើរតែទាំងអស់ បានរៀបរាប់ថា

ខ្ញុំរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ជាមួយកូន។ ប្តីរបស់ខ្ញុំឈ្មោះ ម៉េ


ធី វាសនា ប្រជាជនថ្មីមកពីទីក្រុងភ្នំពេញ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានបាត់បង់សមាជិកគ្រួសារស្ទើរតែទាំងអស់។ (ស៊ាង ចិន្តា/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ង អាន ហើយខ្ញុំមានកូនប្រុសស្រីចំនួន ៥នាក់។ ឪពុករបស់ខ្ញុំឈ្មោះ ធី និងម្តាយឈ្មោះ សន ហើយខ្ញុំជា

---

[10] ធី វាសនា «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

កូនទី៣ក្នុងចំណោមបងប្អូន ៣នាក់។ ខ្ញុំកើតនៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន។ កាលនៅពីវ័យកុមារ ខ្ញុំរៀនសូត្រនៅសាលាបឋមសិក្សាវត្តគ្រូអ៊ុករហូតដល់ថ្នាក់ទី៩(សង្គមចាស់)។ បន្ទាប់មក ខ្ញុំរស់នៅជាមួយបងស្រីនៅទីរួមខេត្តកំពង់ចាម និងបន្តចូលរៀននៅសាលាបឋមសិក្សាទួលថ្ម រហូតដល់ថ្នាក់ទី៦(សង្គមចាស់)។ បន្ទាប់ពីរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឃើញមានបាតុកម្មបានផ្ទុះឡើង និងក្បួនបាតុករដង្ហែ ចូលមកដល់ទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ ដល់១៩៧២ ខ្ញុំបន្តស្នាក់នៅជាមួយគ្រួសារនៅទីរួមខេត្តកំពង់ចាម ប៉ុន្តែពេលនោះខ្ញុំបានឈប់រៀនទៅហើយ ព្រោះសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហមកំពុងផ្ទុះឡើងកាន់តែខ្លាំងឡើងៗ។ កងទ័ពខ្មែរក្រហម បានបើកការវាយប្រហារ និងរំកិលចូលមកទីរួមខេត្តជារៀងរាល់ថ្ងៃ។ នៅពាក់កណ្តាលឆ្នាំ១៩៧៣ ទីរួមខេត្តកំពង់ចាមត្រូវបានឡោមព័ទ្ធដោយកងទ័ពខ្មែរក្រហម។ ខ្ញុំ និងគ្រួសារ នាំគ្នារត់ទៅជិះកប៉ាល់របស់ទាហាន លន់ នល់ ទាំងយប់មកទីក្រុងភ្នំពេញ។ នៅតាមដងទន្លេពីទីរួមខេត្តកំពង់ចាមទៅកាន់ទីក្រុងភ្នំពេញ កប៉ាល់របស់ទាហាន លន់ នល់ ដែលកំពុងតែដឹកជញ្ជូនប្រជាជនជម្លៀសនៅទីរួមខេត្តកំពង់ចាមនោះ ទទួលរងការវាយប្រហារពីកងទ័ពខ្មែរក្រហមជាបន្តបន្ទាប់។ យ៉ាងណាក៏ដោយ កប៉ាល់របស់ទាហាន លន់ នល់ បានចេញមកធ្វើអន្តរាគមន៍ដោយបានបាញ់គ្រាប់ទប់ទល់ និងបើកផ្លូវសុវត្ថិភាពឱ្យកប៉ាល់ដែលដឹកប្រជាជនបន្តដំណើរទៅមុខទៀត។ ខ្ញុំ និងគ្រួសារ មកដល់ទីក្រុងភ្នំពេញនៅព្រឹកបន្ទាប់ និងទៅស្នាក់នៅម្តុំស្ទឹងមានជ័យ។ បន្ទាប់មក ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកែសុងគីម និងរៀនថ្នាក់ទី៥។

រហូតមកដល់ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម បានវាយបែកភ្នំពេញ និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ នៅពេលនោះ ខ្ញុំបែកពីឪពុកម្តាយរបស់ខ្ញុំ ប៉ុន្តែក្រោយមក ខ្ញុំទទួលបានដំណឹងថា គាត់ទាំងពីរបានមកដល់ភូមិកំណើតវិញ។ ខ្ញុំ និងគ្រួសារ របស់បងស្រី បានដើរចេញពីទីក្រុងភ្នំពេញទៅតាមព្រែកព្នៅ និងចំណាយរយៈពេលកន្លះខែទើបបានមកដល់ស្រុកកំណើត។ បន្ទាប់ពីមកដល់ភូមិ ខ្ញុំរស់នៅជាមួយយាយ និងត្រូវបានខ្មែរក្រហមដាក់ធ្វើការងាររែកដីនៅក្នុងភូមិ។ នៅឆ្នាំ១៩៧៦ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅតាំងគោក។ គ្រួសាររបស់ខ្ញុំត្រូវបានដឹកតាមសាឡាងទៅពាមជីកង និងបន្ទាប់មក យើងត្រូវជិះឡានទៅតាំងគោក ខេត្តកំពង់ធំ។នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានដាក់ខ្ញុំឱ្យធ្វើការនៅកងចល័តស្រុកដើម្បីទៅរែកដី និងលើកទំនប់នៅតាមការ រដ្ឋានកំពង់ថ្ម។ ខ្ញុំត្រូវងើបពីម៉ោង៥ព្រឹក ទៅប្រជុំជួរ ហើយចាប់ផ្តើមធ្វើការដល់ម៉ោង១១ព្រឹក ទើបខ្ញុំអាចឈប់សម្រាកហូបបបរបាន។ ខ្ញុំបន្តធ្វើការពីម៉ោង១រសៀល រហូតដល់ម៉ោង ៥ល្ងាច ដឹកនាំដោយប្រធានក្រុមឈ្មោះមិត្តសេង។ នៅឆ្នាំ១៩៧៨ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅភ្នំសន្ទុកលើករងដំឡូង ដោយក្នុងម្នាក់ត្រូវធ្វើឱ្យបានប្រវែង ១០០ម៉ែត្រ។ ខ្ញុំធ្វើការនៅការដ្ឋាន រហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិចូលមករំដោះប្រជាជនចេញពីការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំរួចផុតពីសេចក្តីស្លាប់នៅពេលនោះ ហើយមកវិលត្រលប់មករស់នៅជួបជុំគ្រួសារវិញ។

ខ្មែរក្រហមសម្លាប់ឪពុកនិងម្ដាយដែលមានផ្ទៃពោះនិងប្អូនៗរបស់ខ្ញុំចូលក្នុងរណ្ដៅទាំងអស់

ស្រេង ស៊ីថា[11]មានស្រុកកំណើតនៅភូមិចុងកោះជើង ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ប្រជាជនថ្មីមកពីទីក្រុងភ្នំពេញ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រំឭកពីការកាប់សម្លាប់ឪពុកម្ដាយ និងបងប្អូនរបស់គាត់ទម្លាក់ចូលក្នុងរណ្ដៅសាកសពរួមយ៉ាងព្រៃផ្សៃ ថា៖

ខ្ញុំឈ្មោះ ស្រេង ស៊ីថា បច្ចុប្បន្នរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំ


ធី វាសនា ប្រជាជនថ្មីមកពីទីក្រុងភ្នំពេញ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានបាត់បង់សមាជិកគ្រួសារ ស្ទើរតែទាំងអស់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គឺជាអតីតគ្រូបង្រៀនថ្នាក់ទី១នៅសាលាបឋមសិក្សាទីប្រជុំ។ ខ្ញុំរៀបការជាមួយប្ដីរបស់ខ្ញុំឈ្មោះ អ៊ុត ម៉ៅ និងមានកូនប្រុសស្រីទាំងអស់ចំនួន ៤នាក់។ ខ្ញុំមានឪពុកឈ្មោះ ស ស្រេង គឺជានាយទាហាន លន់ នល់ និងម្ដាយឈ្មោះ មែន ជា។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូន ៧នាក់។

នៅចុងឆ្នាំ១៩៧៨ ឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ជាមួយគ្រួសារប្រជាជន១៧មេសាជាច្រើនផ្សេងទៀតនៅក្នុងភូមិប្រមាត់ដី។ ពេលនោះ ខ្ញុំមិនបានរស់នៅជិតគ្រួសារ ទេ ព្រោះខ្ញុំត្រូវបានបញ្ជូនទៅធ្វើត្រីនៅឯទន្លេសាបក្នុងខេត្តកំពង់ធំ និងបោចស្លឹលនៅខេត្តព្រះវិហារ។

[11] ស្រេង ស៊ីថា «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្ដា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាទួលថ្មរហូតដល់បញ្ចប់ថ្នាក់៧(សង្គមចាស់)។ ខ្ញុំបានប្រឡងចូលរៀនថ្នាក់ទី៦នៅវិទ្យាល័យព្រះសីហនុ។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញមានការធ្វើបាតុកម្មនៅទីរួមខេត្តកំពង់ចាម។ បាតុកម្មបានអូសបន្លាយរយៈពេលប្រហែលជា ២ទៅ ៣ថ្ងៃ។ មិនយូរប៉ុន្មាន បន្ទាប់ពីបាតុកម្មបានបញ្ចប់ សង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហមបានផ្ទុះឡើង។ នៅពេលនោះ ឪពុករបស់ខ្ញុំ គឺជានាយទាហាន លន់ នល់ ថ្នាក់អនុសេនីយ៍ឯក។ ចាប់ពីចុងឆ្នាំ ១៩៧០ ដល់ឆ្នាំ១៩៧២ សង្គ្រាមរវាងទាហាន លន់ នល់ ដែលឈរជើងនៅព្រំប្រទល់ចូលទីរួមខេត្តកំពង់ចាម និងកងទ័ពខ្មែរក្រហមដែលឈរជើងនៅតាមភូមិ បានផ្ទុះការប្រយុទ្ធកាន់តែខ្លាំងឡើង។ នៅឆ្នាំ១៩៧៣ ស្ថានភាពកាន់តែមិនស្រួល ឪពុករបស់ខ្ញុំ បានយកសមាជិកគ្រួសារជិះយន្តហោះនៅព្រលានយន្តហោះស្ថិតនៅម្តុំវាលវង់ ខេត្តកំពង់ចាម សំដៅទៅទីក្រុងភ្នំពេញ ដើម្បីរកកន្លែងសុវត្ថិភាព។ បន្ទាប់មក ឪពុករបស់ខ្ញុំបានផ្លាស់ទៅធ្វើការនៅឯកំពង់សោម។ ខ្ញុំ និងគ្រួសារបានទៅរស់នៅកំពង់សោមជាមួយឪពុករបស់ខ្ញុំនៅទីនោះ។ នៅឆ្នាំ១៩៧៤ ឪពុករបស់ខ្ញុំ ត្រូវបានផ្លាស់មកធ្វើការភ្នំពេញវិញ។ នៅពេលនោះ ឪពុកនិងម្តាយរបស់ខ្ញុំ បានទិញផ្ទះមួយនៅម្តុំវត្តទឹកល្អក់។ ខ្ញុំបានចូលរៀននៅសាលាឯកជនមួយឈ្មោះ តារាសាស្រ្ត ដោយបានរៀនត្រឹមតែថ្នាក់ទី៤ទេ។ ឪពុករបស់ខ្ញុំទទួលបានតួនាទីជាចៅហ្វាយខេត្តកំពត។ ឪពុករបស់ខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តកំពតតាមរយៈយន្តហោះខ្នាតតូច ពីព្រោះតែការធ្វើដំណើរតាមផ្លូវជាតិ គឺមិនមានសុវត្ថិភាព និងអាចទទួលរងការវាយប្រហារពីកងទ័ពខ្មែរក្រហម។ ម្តាយ និងបងប្អូនរបស់ខ្ញុំផ្សេងទៀត គឺបន្តរស់នៅទីក្រុងភ្នំពេញ។ នៅពេលដែលកងទ័ព ខ្មែរក្រហមខិតជិតចូលមកដល់ទីក្រុងភ្នំពេញ ឪពុករបស់ខ្ញុំបានសម្រេចចិត្តជិះយន្តហោះខ្នាតតូចវិលត្រលប់មកភ្នំពេញដើម្បីបានជួបជុំជាមួយគ្រួសារ។ ឪពុករបស់ខ្ញុំបានមកដល់ផ្ទះវិញនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ គឺមួយថ្ងៃមុនពេលកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ នៅវេលាប្រហែលម៉ោង៤រសៀល ខ្ញុំឮស្នូរ ទម្លាក់គ្រាប់បែកនៅម្តុំផ្ទះដែលខ្ញុំរស់នៅ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ។ កងទ័ពខ្មែរក្រហមបានមកគោះទ្វារផ្ទះរបស់ខ្ញុំ ប៉ុន្តែឪពុករបស់ខ្ញុំបានប្រាប់ថា សុំស្នាក់នៅផ្ទះមួយយប់សិន។ នៅព្រឹកថ្ងៃបន្ទាប់ គឺថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានមកប្រាប់គ្រួសាររបស់ខ្ញុំឱ្យចាកចេញពីទីក្រុងភ្នំពេញត្រឹមតែរយៈពេល ៣ថ្ងៃប៉ុណ្ណោះ។ ភ្លាមនោះ ម្តាយរបស់ខ្ញុំបានរៀបចំយកមុង ភួយ និងខោអាវខ្លះមុនពេលចាកចេញពីផ្ទះ។ គ្រួសាររបស់ខ្ញុំ បានដើមតាមផ្លូវទឹកល្អក់ រហូតដល់ម្តុំអង់តែនទួលគោករួចឆ្ពោះទៅគីឡូម៉ែត្រលេខ៦ និងបន្តឆ្ពោះទៅព្រែកក្តាម ដើម្បីឆ្លងទន្លេទៅខាងកំពង់ចាម។ ខ្ញុំឃើញមានប្រជាជនជាច្រើននាក់ដើរពាសពេញផ្លូវទៅព្រែកក្តាមដែរ។ គ្រួសាររបស់ខ្ញុំបានដើរ ៤ថ្ងៃទើបទៅដល់កំពង់ចម្លងព្រែកក្តាម។ កងទ័ពខ្មែរក្រហម បានសួរស្ទង់ ... 

ខ្ញុំ បានប្រាប់កងទ័ពខ្មែរក្រហមថា គាត់គឺជាអ្នកបើកឡាននៅភ្នំពេញ។ ការស្កាត់សួរអំពីប្រវត្តិលើកទី២ គឺនៅម៉ុំការកោង។ ប្រជាជនជាច្រើននាក់ ដែលត្រូវបានខ្មែរក្រហមស៊ើបដឹងថាធ្លាប់បម្រើការជាគ្រូបង្រៀន ទាហាន ឬមន្ត្រីក្នុងរបប លន់ នល់ ត្រូវបានកងទ័ពខ្មែរក្រហមមិនអនុញ្ញាតឱ្យបន្តដំណើរទៅមុខបាននោះទេ និងក្រោយមកត្រូវបានយកទៅសម្លាប់ចោល។ គ្រួសាររបស់ខ្ញុំបន្តដំណើរទៅដល់ភូមិត្រពាំងស្នោរ និងបានស្នាក់នៅទីនោះប្រហែល ១ខែ។ នៅខែមិថុនា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំ បានលួចរត់ទាំងយប់ចេញពីភូមិត្រពាំងស្នោរ ដើម្បីមកភូមិកំណើតរបស់ជីដូន នៅភូមិប្រមាត់ដី ឃុំស្វាយទាប ស្រុកចំការលើ។ ចាប់ពីឆ្នាំ១៩៧៦ ដល់១៩៧៧ ខ្ញុំចូលធ្វើការក្នុងកងចល័តនារីឃុំស្វាយទាប ដោយបានដើរលើកទំនប់ ជីកដី និងភ្ជួររាស់។ ចំណែកឯ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ ត្រូវបានដាក់ឱ្យធ្វើការនៅតាមកងផ្សេងៗរៀងៗខ្លួន។ នៅថ្ងៃមួយ ខ្ញុំនិងកងចល័តនារី ត្រូវបានប្រាប់ឱ្យទៅប្រជុំនៅផ្ទះលេខាភូមិភាគ គឺមិត្ត កែ ពក។ នៅពេលនោះ ខ្ញុំឃើញមានកងចល័តជាច្រើនបានអង្គុយប្រជុំ។ មិត្ត កែ ពក បាននិយាយប្រាប់ឱ្យយើងគ្រប់គ្នាខិតខំធ្វើការងារ។ នៅឆ្នាំ១៩៧៨ កងចល័តនារីរបស់ខ្ញុំ ត្រូវបានផ្លាស់ប្តូរទៅលើកទំនប់នៅខេត្តកំពង់ធំវិញ គឺទំនប់១មករា ដោយចំណាយអស់រយៈពេល ៣ខែ។ ការដ្ឋានទំនប់១មករា មិនទាន់បញ្ចប់នៅឡើយទេ ប៉ុន្តែកងចល័តនារីរបស់ខ្ញុំត្រូវខ្មែរក្រហមបានផ្លាស់មកកាន់ភូមិប្រមាត់ដីវិញ។ បន្ទាប់ពីមកដល់ភូមិបានប្រហែល ២ទៅ៣ខែ ខ្ញុំត្រូវបានមិត្ត រឿន ដែលជាប្រធានកងចល័តឃុំជ្រើសរើសចូលក្នុងកងកម្លាំងស្រួចដែលមានសមមិត្តប្រហែល ២៥នាក់ ដើម្បីទៅធ្វើការនៅកន្លែងនេសាទត្រី នៅខេត្តកំពង់ធំ និងទៅបោចវល្លិ៍នៅខេត្តព្រះវិហារ។ ខ្ញុំបាននិយាយលាឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំ មុនពេលចាកចេញទៅ។ បន្ទាប់ពីបានទៅធ្វើការឆ្ងាយចេញពីភូមិរយៈពេល ៣ខែ ខ្ញុំបានមកលេងផ្ទះបាន ៣ថ្ងៃ។ នៅពេលដែលខ្ញុំចេញពីផ្ទះវិលត្រលប់ទៅធ្វើការងារវិញ ប្អូនប្រុសរបស់ខ្ញុំបានសុំខ្ញុំទៅជាមួយ។ ប៉ុន្តែខ្ញុំមិនបានយកប្អូនរបស់ខ្ញុំទៅជាមួយ ពីព្រោះខ្ញុំធ្វើការបោចវល្លិ៍នៅក្នុងព្រៃក្បែរភ្នំត្បែង មានស្ថានភាពពិបាករស់នៅណាស់។ ៤ថ្ងៃបន្ទាប់ពីខ្ញុំចាកចេញពីផ្ទះលើកនេះ ខ្ញុំក៏ទទួលបានដំណឹងថា គ្រួសាររបស់ខ្ញុំ រួមមាន ឪពុក ម្តាយដែលកំពុងពពោះជិតគ្រប់ខែ និងបងប្អូនទាំងអស់ ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់។ នៅពេលទទួលដំណឹងពីការស្លាប់របស់គ្រួសារ ខ្ញុំគ្មានព្រលឹងនៅក្នុងខ្លួននោះឡើយ។ ប៉ុន្តែមិត្ត រឿន បាននិយាយលើកទឹកចិត្តខ្ញុំឱ្យពង្រឹងស្មារតីក្នុងការធ្វើការងារ ពីព្រោះខ្ញុំត្រូវបានដាក់ស្ថិតនៅក្នុងប្រជាជនមានប្រវត្តិមិនល្អ ដែលប្រឈមការចាប់យកទៅសម្លាប់គ្រប់ពេលវេលា។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ទីរួមខេត្តកំពង់ចាម កងចល័តទាំងអស់ត្រូវបានរំសាយ។ នៅពេលនោះ ខ្ញុំនិងមិត្តនារី ៣នាក់ទៀត បានចែវទូកតាមទន្លេត្រលប់មកភូមិវិញ ហើយកងទ័ពខ្មែរក្រហមដែលសេសសល់បានស្កាត់ស្ទាក់យើងនៅតាមផ្លូវ។ ខ្ញុំ និងមិត្តនារីទាំងអស់សំណាងល្អ ត្រូវបានកងទ័ពខ្មែរក្រហម ដោះលែងវិញ ហើយយើងក៏បន្តចែវទូករហូតមកដល់ភូមិវិញ។ ខ្ញុំដឹងថា មានប្រជាជនជាច្រើនគ្រួសារក៏បានចែវទូកនៅពីក្រោយខ្ញុំដែរ ប៉ុន្តែត្រូវបានខ្មែរក្រហមចាប់យកទៅ

សម្លាប់ទាំងអស់។ ទោះបីជាខ្ញុំរួចផុតពីសេចក្តីស្លាប់នាពេលនោះ ប៉ុន្តែខ្ញុំបានបាត់បង់សមាជិកគ្រួសារទាំងអស់។

## ៣. សេចក្តីបញ្ចប់

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំដើមឆ្នាំ១៩៧៩ អ្នកភូមិទី៨ ដែលរួចផុតពីសេចក្តីស្លាប់ ហើយបានផ្លាស់ទីឃ្លាតឆ្ងាយពីភូមិនាគ្រានោះ ក៏បានវិលត្រលប់មកភូមិកំណើតវិញ ដោយធ្វើដំណើរថ្មើរជើងជាច្រើនថ្ងៃ ដើម្បីស្វែងរកសាច់ញាតិបងប្អូន និងបន្តជីវភាពរស់នៅរៀងៗខ្លួនវិញ។ ប្រជាជនជាច្រើនត្រូវបានដឹកយកទៅសម្លាប់នៅវត្តក្បាលកោះ ហើយរណ្តៅសាកសពរួមជនរងគ្រោះក្នុងរបបខ្មែរក្រហម ត្រូវបានទឹកជំនន់ជន់លិច និងបាក់ដីចូលទៅទឹកទន្លេ។ ដោយឃើញអំពីសារសំខាន់នៃការចងចាំដល់ជនរងគ្រោះ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានស្នើសុំដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ជួយសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធសម្រាប់សហគមន៍ ដែលស្ថិតនៅកណ្តាលចំការពោតក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ស្តូបរំឭកសម្រាប់សហគមន៍ ដើរតួនាទីជាទីតាំងរំឭកដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម និងជាទីតាំងអប់រំសហគមន៍សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អាចនិយាយប្រាប់បទពិសោធន៍របស់ខ្លួនទៅកាន់សិស្សានុសិស្ស យុវជន យុវនារី ជំនាន់ក្រោយ ព្រមទាំងអ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ។

៤. ឯកសារយោង


1. ផេង ពង្សរ៉ាស៊ី, ដេវីដ ឆេនដល័រ, គ្រីស្តូហ្វ័រ ឌៀរីង, សុភ័ក្រ ភាណា, «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» (បោះពុម្ពលើកទី២ នៅប្រទេសកម្ពុជា ឆ្នាំ២០២០), ទំព័រ៣៩-៤០
2. មជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកសារលេខD00591, «ពោងផែនការ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែករបស់បក្ស ឆ្នាំ១៩៧៧-១៩៨០», បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា
3. សៀវភៅ៖ «ការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហម», រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ, ឆ្នាំ២០១៤
4. តាំង រីនិត, «KR used 1978 floods to massacre thousands of villagers», កាសែតខ្មែរថាម៍ ជាភាសាអង់គ្លេស, ចុះផ្សាយនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ (ចូលអាននៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅគេហទំព័រ៖ https://www.khmertimeskh.com/501585632/kr-used-1978-floods-to-massacre-thousands-of-villagers/ )
5. ម៉ៅ វណ្ណា «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា
6. ជី វាសនា «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា
7. ស្រេង ស៊ីថា «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា
8. អាន រី «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

9. ស៊ឹង គឹមស្រ៊ុន «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

10. ឡុង គឹមស្រ៊ាង «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

11. លឹម អេង «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» សម្ភាសន៍ដោយ ស៊ាង ចិន្តា មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅខែកុម្ភៈ ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

12. ហុក ណៃវេង, «ប្រវត្តិសាស្ត្រផ្ទាល់មាត់៖ បទពិសោធន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម», សម្ភាសន៍ដោយ ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា